ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / 06 / 2012
ម៉ោង (Time/Heure): 09:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ពុធ ទី ៣០ ខែ ឧសភា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្ដី - ថ្ងៃទី ៦៦

រៀបចំដោយ: សែ កុលវុឌ្ឍី និង Matteo CRIPPA

| |
|---|
| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី លោក Matteo CRIPPA លោកស្រី សែ កុលវុឌ្ឍី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក វេង ហ៊ត់, លោក Vincent DE WILDE D'ESTMAEL, លោក Dale LYSAK, លោក Tarik Abdulhak. |
| ជនជាប់ចោទ៖ អៀង សារី, នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Michiel PESTMAN , លោក Jasper PAUW |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |

| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក ឡោ ជុនធី, លោក សំ សុគង់, លោកស្រី ទី ស្រីនណា, លោកស្រី មេធាវី Laure DESFORGES, លោក Barnabé NEKUIE, លោក ហុង គីមសួន, លោកស្រី ស៊ិន សូវន, លោក វ៉ែន ពៅ, លោក គីម ម៉េងឃី. |
| សាក្សី៖ លោក នី កន (TCW-487), លោក ស គីមល្អុត (TCW-583) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោក Philippe GOUT, លោក ម៉ម រិទ្ធា និង លោក លឹម ប៊ុនហេង (មេធាវីប្រឹក្សាសាក្សី) |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ៩.០០ | បញ្ចប់ម៉ោង៖ ១៦.០៥ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៤០ | បញ្ចប់ម៉ោង៖ ១១.០០ |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៥០ | បញ្ចប់ម៉ោង៖ ១៥.១០ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៥ ម៉ោង | | |

| **កិច្ចដំណើរការនីតិវិធី៖** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
| សំណើសុំលះបង់សិទ្ធិចូលរួមដំណើរការសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ | មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី នួន ជា | ០៩.០១<br>១២.០២ | ០៩.០២<br>១២.០៤ |
| ការបញ្ជាក់របស់អង្គជំនុំជម្រះចំពោះឯកសាររបស់សហព្រះរាជអាជ្ញា | អង្គជំនុំជម្រះ | ០៩.០៤ | ០៩.០៦ |
| ការតាំងសំណួរទៅសាក្សី នី កន TCW-487 | អង្គជំនុំជម្រះ<br>មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី អៀង សារី<br>មេធាវីការពារក្តី ខៀវ សំផន | ០៩.០៦ | ១៤.៤៧ |

| | | | |
|---|---|---|---|
| ការតាំងសំណួរទៅសាក្សី ស គឹមល្អុត TCW-583 | សហព្រះរាជអាជ្ញា | ១៥.១១ | ១៦.០២ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**សំណើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់**

ជនជាប់ចោទ អៀង សារី និង នួន ជា តាមរយៈមេធាវីរបស់ខ្លួន បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ ដោយចូលរួមសវនាការពីបន្ទប់រង់ចាំខាងក្រោមបន្ទប់សវនាការ ហើយបានប្រគល់លិខិតលះបង់សិទ្ធិមកឱ្យក្រឡាបញ្ជី។ អង្គជំនុំជម្រះអនុញ្ញាតិតាមសំណើ។

**ការបញ្ជាក់របស់អង្គជំនុំជម្រះចំពោះឯកសាររបស់សហព្រះរាជអាជ្ញា**

អង្គជំនុំជម្រះបានផ្តល់ការបញ្ជាក់ទៅលើឯកសារពីរដែលស្នើសុំដាក់ដោយសហព្រះរាជអាជ្ញា ក្នុងការដេញដោលចំពោះសាក្សី TCW-487 ។ អង្គជំនុំជម្រះបានផ្តល់ពត៌មានបន្ថែមអំពីកាលបរិច្ឆេទនៃការទទួលឯកសារ និងឈ្មោះបុគ្គលដែលបានទទួល។ ឯកសារទាំងពីរនេះគឺជាទូរលេខ ៣០៦ និង ៣០៧ ដែលមានលេខ D252.12, D252.13។

**ការតាំងសំណួរទៅសាក្សី នី កន TCW-487**

អង្គជំនុំជម្រះ និងមេធាវីការពារក្តី នួន ជា អៀង សារី និង ខៀវ សំផន បានតាំងសំណួរទៅសាក្សី នី កន។ ក្នុងអំឡុងពេលនៃការតាំងសំណួរ អង្គជំនុំជម្រះបានណែនាំទៅមេធាវីការពារក្តី នួន ជា មិនឱ្យសួរសំណួរទាក់ទងនឹងការធ្វើសម្បថរបស់សាក្សីនេះនៅមុនពេលមកផ្តល់សក្ខីកម្មនៅតុលាការ និងមិនអនុញ្ញាតិឱ្យដាក់ឯកសារដែលមេធាវីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះអនុលោមតាមវិធាន៨៧ អង្គជំនុំជម្រះបានប្រគល់ការតាំងសំណួរទៅក្រុមមេធាវីការពារក្តី អៀង សារី។

**ការតាំងសំណួរទៅសាក្សី ស គឹមល្អុត ហៅមី TCW-583**

អង្គជំនុំជម្រះបានតាំងសំណួរទៅសាក្សី ស គឹមល្អុត អំពីប្រវត្តិរូបរបស់សាក្សី និងបានប្រាប់អំពីសិទ្ធិ និងតួនាទីរបស់សាក្សី។ បន្ទាប់មកសហព្រះរាជអាជ្ញាបានចាប់ផ្តើមតាំងសំណួរទៅសាក្សី។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/1112 | D252.12 | 00020960-00020962<br>00434861-00434863<br>00810029-00810032 | ទូរលេខ ៣០៦៖ ជំរាបបង វ៉ាន់ ជាទីស្នេហា អំពីសំភាសរបស់ភ្ញៀវយូហ្គោស្លាវី<br>Telegram 306 : To Beloved Brother Vann about the interview with guests from Yugoslavia<br>Télégramme 306: au très cher frère Vann au sujet de l'entretien avec les invités yougoslaves | P | 00434861-63 | 00434861-63 | 00810029-32 |
| E3/1113 | D252.13 | 00001080-00001082<br>00434864-00434866<br>00623009-00623012 | ទូរលេខ ៦១៖ សូមជំរាបមក បង ជាទីគោរពស្នេហា អំពីទស្សនៈកិច្ចរបស់អ្នកកាសែត យូហ្គោស្លាវី នៅភូមិភាគពាយ័ព្យ<br>Telegram 61 : To respected and beloved Brother about The visit paid by Yugoslavian reporters to Northwest Zone<br>Télégramme 61: Respecté et aimé frère à propos de la visite effectuée par des journalistes yougoslaves à Zone Nord-Ouest | P | | | |
| E3/1611 | D369/16 | 00486479-00486482<br>00491298-00491301<br>00509800-00509804 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី NY Kân នី កន ចុះថ្ងៃទី 09-03-2010<br>Written Record of Interview of Witness NY Kân នី កន Dated 09-03-2010<br>Procès verbal d'audition de témoin NY Kân នី កន en date du 09-03-2010 | P | | | |
| E3/1156 | D366/7.1.214 | 00032944-00032945<br>00524507-00524508<br>00807142-00807143 | លិខិតពី កន និង មុត ជូនចំពោះបងជាគោរព ស្នេហា<br>Letter from Kân and Mut to "Respected Brother"<br>Lettre de Kân et Mut adressée au "respecté frère" | P | | | |
| E3/460 | D91/21 | 00204127-00204130<br>00223623-00223626<br>00529337-00529340 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នី កន ថ្ងៃទី១២ ១២ ២០០៧<br>Written Record of Interview of NY Kân<br>Procès verbal d'audition de NY Kân | P | 00204129 | 00223626 | 00529340 |
| E3/1610 | D91/22 | 00204131-00204134<br>00702360-00702364<br>00529341-00529345 | កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នី កន ថ្ងៃទី១៣ ១២ ២០០៧<br>[Corrected 1] Written Record of Interview of NY Kân<br>[Corrigé 1] Procès verbal d'audition de NY Kân | P | 02044134, 00204132 | | |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ អៀង សារី (០៩.០២) និង នួន ជា (១២.០២) ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនិងកំណត់ហេតុនេះ)។

- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី, នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវសំផនត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១២។ ដោយឡែកជនជាប់ចោទ អៀង សារី ឱ្យនាំខ្លួនមកបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ ប្រសិនបើជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិក្នុងការមានវត្តមាននៅក្នុងបន្ទប់សវនាការ។

- បង្គាប់ឱ្យនាំសាក្សីត្រឡប់ទៅកាន់កន្លែងសម្រាក និងនាំគាត់ត្រឡប់មកបន្ទប់សវនាការវិញនៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១២។

**<u>កាលបរិច្ឆេទបន្តសវនាការ៖</u>**

សវនាការនឹងបន្តនៅថ្ងៃ ព្រហស្បត្តិ៍ ទី ៣១ ខែ ឧសភា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

សែ គុលឧត្តម Matteo CRIPPA